ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ....

រាជធានីភ្នំពេញថ្ងៃទី...ខែ... ឆ្នាំ ២០១៦

## ជម្រាបជូន

**ឯកឧត្តម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ**: សំណើជួយជំរុញផែនការថវិកាឃុំ.សង្កាត់សម្រាប់ឆ្នាំនីមួយៗ និងផ្តល់អនុលោមភាពគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំឲ្យទាន់ពេលវេលា ក្នុងការអនុវត្តថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

**យោង**: ប្រកាសលេខ ៣៣១ សហវ.ប្រក ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមជម្រាបជូន ÷ **ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** មេត្តាជួយពង្រឹង និងជំរុញផែនការថវិកាឃុំ សង្កាត់ឆ្នាំ២០១៧ ឲ្យទាន់ពេលវេលាដើម្បីឲ្យរតនាគាររាជធានី ខេត្តមានលទ្ធភាពបញ្ចូលទិន្នន័យគម្រោងថវិកាឃុំ សង្កាត់ចូលទៅក្នុងប្រពន្ធ័ FMIS ទាន់ពេលវេលាសម្រាប់ឆ្នាំ២០១៧នេះតទៅ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម** កំណត់ពេលវេលាអនុលោមភាពគម្រោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំនៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ ឲ្យបានចប់សព្វគ្រប់ ដើម្បីចាប់ផ្តើមអនុវត្តគម្រោងថវិការបស់ឃុំ សង្កាត់ចាប់ពីថ្ងៃទី០១ខែមករា នៃឆ្នាំថវិកាឆ្នាំថ្មី ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដោយស្មោះពីខ្ញុំ ។

Adm & F.D

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**...ជុំ គឹមឡេង**

ចម្លងជូន
.ក្រសួងមហាផ្ទៃ
.អគ្គនាយកដ្ឋានរតនាគារជាតិ
.គ្រប់សាលារាជធានី ខេត្ត
.គ្រប់ឃុំ សង្កាត់
.ឯកសារ-កាលប្បវត្តិ

23/12/16

23/12/2016